PHL ConnectED

# ភ្ជាប់ក្រុមគ្រួសាររបស់សិស្សថ្នាក់ មត្តេយ្យ - ១២ នៅទីក្រុងហ្វីឡាដែលហ្វ្យ៉ា ជាមួយអ៊ីនធឺណិត សម្រាប់ការសិក្សាតាមកុំព្យូទ័រ

តើក្រុមគ្រួសាររបស់លោកអ្នកត្រូវការប្រើប្រាស់អ៊ីនធឺណិតនៅផ្ទះដែរឬទេ? តើលោកអ្នកអាចចូលប្រើ វ៉ាយហ្វាយបានតែតាមទូរស័ព្ទដៃ មែនដែរឬទេ?

PHLConnectED អាចជួយក្រុមគ្រួសាររបស់លោកអ្នកឱ្យមានអ៊ីនធឺណិត ដើម្បីអាចឱ្យកូនដែលរៀនថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២ របស់លោកអ្នក អាច ភ្ជាប់ និង រៀន បាន។

**តើ PHLConnectED គឺជាអ្វី?**
PHLConnectED គឺជាកម្មវិធីថ្មីរបស់ក្រុង ដើម្បីជួយក្រុមគ្រួសាររបស់សិស្ស ថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២ ឱ្យទទួលបានការតភ្ជាប់ទៅ អ៊ីនធឺណិតដែលមានល្បឿនលឿន និង គួរឱ្យទុកចិត្តបាន។

សិស្សានុសិស្ស និង ក្រុមគ្រួសារ ដែលមានសិទ្ធិ អាចចុះឈ្មោះប្រើអ៊ីនធឺណិតរហូតដល់ទៅ ២ ឆ្នាំ ជាមួយ Internet Essentials របស់ក្រុមហ៊ុន Comcast ដោយឥតគិតថ្លៃ ឬ ផ្អែកទៅលើសេចក្តីត្រូវការ អាចប្រើ ហតស្ពត របស់ក្រុមហ៊ុន T-Mobile ដោយឥតគិតថ្លៃ រហូតដល់ ខែមិថុនា ឆ្នាំ ២០២២ ។

**តើអ្នកណាអាចភ្ជាប់បានតាមរយៈ PHLConnectED?**
សិស្សានុសិស្ស និង ក្រុមគ្រួសារ ដែលបច្ចុប្បន្ននេះគ្មានអ៊ីនធឺណិត (ប្រើខ្សែ/នៅក្នុងផ្ទះ) បែបណាមួយ ឬ មានអ៊ីនធឺណិតតែតាមរយៈទូរស័ព្ទដៃរបស់ពួកគេ អាចមានសិទ្ធិប្រើប្រាស់អ៊ីនធឺណិតនៅតាមផ្ទះ តាមរយៈអ៊ីនធឺណិត Essentials របស់ក្រុមហ៊ុន Comcast ។

សិស្សានុសិស្ស និង ក្រុមគ្រួសារ ដែលគ្មានទីលំនៅ ឬ គ្មានទីលំនៅពិតប្រាកដ អាចមានលក្ខណៈគ្រប់គ្រាន់សម្រាប់ ហតស្ពត (cellular hotspot) ។

**វិធីភ្ជាប់**
បើសិនជាលោកអ្នកចង់ស្វែងយល់បន្ថែមអំពី PHLConnectED និង ចង់ដឹងថាតើលោកអ្នកមានសិទ្ធិឬ ទេ សូមទូរស័ព្ទទៅលេខ ២-១-១ ហើយជ្រើសយកលេខ ១ ។ ខ្សែទូរស័ព្ទសំខាន់ បើក ២៤ ម៉ោង ក្នុងមួយថ្ងៃ ៧ ថ្ងៃ ក្នុងមួយសប្តាហ៍ និង មានច្រើនជាង ១៥០ ភាសា។

City of Philadelphia